ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ..០៥...សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង ប្រចាំនៅរាជធានីភ្នំពេញ

៙៙៙+៚៚៚

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញសេចក្តីសំរេចលេខ ៥៥សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣

-ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតការិយាល័យសន្តិសុខថ្នាក់ក្រុង ប្រចាំនៅរាជធានីភ្នំពេញ ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | កែប ជុតិមា | អភិបាលរាជធានីភ្នំពេញ | ប្រធាន |
| ២-ឯកឧត្តម | ចាន់ ស៊ីណា | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាល-រងទី ១ រាជធានីភ្នំពេញ | អនុប្រធាន |
| ៣-លោកឧត្តមសេនីយ៍ទោ | ព្រហ្ម ឌិន | មេបញ្ជាការយោធភូមិភាគពិសេស | អនុប្រធាន |
| ៤-លោកឧត្តមសេនីយ៍ត្រី | សួន ឈាងលី | ស្នងការនគរបាលរាជធានីភ្នំពេញ | សមាជិក |
| ៥-លោកឧត្តមសេនីយ៍ត្រី | ខន្ធ ពិសេន | មេបញ្ជាការកងរាជអាវុធហត្ថ | សមាជិក |
| ៦-លោក | ម៉ាន់ ឈឿន | នាយខុទ្ទកាល័យសាលាក្រុង | សមាជិក |
| ៧-លោកវរៈសេនីយ៍ឯក | មួង ឃឹម | ស្នងការរងនគរបាលរាជធានីភ្នំពេញ | សមាជិក |
| ៨-លោក | សុខ លក្ខិណា | នាយរងខុទ្ទកាល័យសាលាក្រុង | សមាជិក |
| ៩-លោក | សៅ គុនធុន | អនុប្រធានការិយាល័យសរុបសាលាក្រុង | សមាជិក |
| ១០-លោក | អ៊ាន សុឃីម | មន្ត្រីការិយាល័យសរុបសាលាក្រុង | សមាជិក |
| ១១-លោក | ជូ ម៉េងចាន់ | មន្ត្រីរដ្ឋបាលមូលដ្ឋានសាលាក្រុង | សមាជិក |

**ប្រការ២** : ការិយាល័យសន្តិសុខថ្នាក់ក្រុងមានភារកិច្ច :

-ផ្សព្វផ្សាយ និងចាត់តាំងអនុវត្តផែនការលេខ ០១ផក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ ស្តីពីផែនការការពារសន្តិសុខ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-រៀបចំបង្កើតការិយាល័យសន្តិសុខថ្នាក់ខណ្ឌ សង្កាត់ តាមសេចក្តីសំរេចលេខ ០១សណរ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ទទួលគោលការណ៍ ផែនការផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់កណ្តាល និងផ្សព្វផ្សាយដល់ការិយាល័យសន្តិសុខថ្នាក់ខណ្ឌ សង្កាត់ ព្រមទាំងណែនាំចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធិភាព ។

-រៀបចំចាត់ចែង និងប្រើប្រាស់កម្លាំងគ្រប់ប្រភេទតាមផែនការកំណត់ និងណែនាំឱ្យកម្លាំងទាំងនោះអនុវត្តបានត្រឹមត្រូវ តាមបទបញ្ជា នីតិវិធីរបស់គ.ជ.ប និងច្បាប់បោះឆ្នោត ។

-ចាត់ចែងប្រើប្រាស់មធ្យោបាយ ឧបករណ៍សំភារៈរបស់បណ្តាអង្គភាពដែលមានស្រាប់ដើម្បីបំរើដល់កិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោត ។

-ប្រមូលផ្តុំព័ត៌មាន និងសភាពការណ៍ផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់ក្រោម ឬកសរុបរាយការណ៍ផ្ញើជូនមកការិយាល័យសន្តិសុខថ្នាក់កណ្តាលឱ្យបានទាន់ពេលវេលា ។

-ពិនិត្យដោះស្រាយពាក្យបណ្តឹង ឬឧប្បត្តិហេតុផ្សេងៗពាក់ព័ន្ធដល់សន្តិសុខនៃការបោះឆ្នោតដែលកើតឡើងក្នុងរង្វង់ភូមិសាស្ត្ររបស់ខ្លួន និងធ្វើរបាយការណ៍ជូនមកកាន់ការិយាល័យសន្តិសុខថ្នាក់កណ្តាលរៀងរាល់ ១៥ថ្ងៃម្តង ។ ករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់មកការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ធ្វើគំរោងថវិកា ឧបករណ៍សំភារៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទបំរើការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់មណ្ឌលភ្នំពេញ ដាក់ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាលពិនិត្យសំរេច ។

-ធ្វើរបាយការណ៍ចំណូលចំណាយថវិកា និងការប្រើប្រាស់ឧបករណ៍សំភារៈ មធ្យោបាយដើម្បី[illegible] គំរោងដែលការិយាល័យសន្តិសុខថ្នាក់កណ្តាលបានធ្វើការបែងចែកដល់ការិយាល័យសន្តិសុខគ្រប់ថ្នាក់ និង[illegible] ទាំងអស់ ។

**ប្រការ ៣**: ការិយាល័យសន្តិសុខថ្នាក់ក្រុងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាក្រុងភ្នំពេញ និងមានសិទ្ធិបង្កើតក្រុមជំនួយការអចិន្ត្រៃយ៍ដើម្បីជាជំនួយក្នុងការតាមដានគ្រប់សភាពការណ៍ និងជួយដឹកនាំបញ្ជាតាមការណែនាំរបស់ប្រធានការិយាល័យសន្តិសុខថ្នាក់ក្រុង ។

**ប្រការ ៤**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ ប្រធានលេខាធិការដ្ឋាន ការិយាល័យសន្តិសុខថ្នាក់កណ្តាល មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០០៣

ឧបនាយករដ្ឋមន្ត្រី

និងជាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល

**ស ខេង**

កន្លែងទទួលៈ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង

-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-លេខាធិការដ្ឋានការិយាល័យសន្តិសុខថ្នាក់កណ្តាល

-ដូចប្រការ ៤

-សាលាក្រុងភ្នំពេញ

-ឯកសារ-កាលប្បវត្តិ